បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២.៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៧ លេខ ៧ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

ពុទ្ធសាសនបណ្ឌិត្យ

ក្រសួងធម្មការ និងសាសនា

* * *

២៥៤២ ឆ្នាំ ខ្លា ទី ៣៧ លេខ ៦ [illegible]

# កម្ពុជសុរិយា

មាតិកា :

- ធម៌ទេសនា
- ប្រវត្តិ - សាស្ត្រ
- ប្រវត្តិបុគ្គល
- អក្សរសាស្ត្រ
- អក្សរសិល្ប៍ខ្មែរ
- ព័ត៌មាន

រក្សាសិទ្ធិ [illegible]

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ [illegible]
[illegible]

តម្លៃ ០៤៦៣.៧ រៀល

ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៧-០២-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០២៩៩/៣២ តែងតាំងឯកឧត្តម ម៉ាស គឹមឆេង ជាអគ្គនាយកអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ២៥៤ |


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ១៨-០២-១៩៩៩ | -អនុក្រឹត្យលេខ ១២ អនក្រ.បក ស្តីពីការបង្កើតក្រុមហ៊ុនសំភារៈកសិកម្ម | ២៥៥ |
| ១៦-០២-១៩៩៩ | -អនុក្រឹត្យលេខ ៣៧ អនក្រ.តត ស្តីពីការកែសំរួលរចនាសម្ព័ន្ធចាត់តាំងក្រសួងការពារប្រទេស | ២៥៦ |
| ១៦-០២-១៩៩៩ | -អនុក្រឹត្យលេខ ៣៨ អនក្រ.តត ស្តីពីការផ្លាស់មន្ត្រីរាជការ | ២៥៨ |
| ១៩-០២-១៩៩៩ | -អនុក្រឹត្យលេខ ៣៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៥៩ |
| ២០-០២-១៩៩៩ | -អនុក្រឹត្យលេខ ៤០ អនក្រ,តត ស្តីពីការជូនមេដាយការងារ | ២៦០ |
| ២២-០២-១៩៩៩ | -អនុក្រឹត្យលេខ ៤១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៦៦ |
| ២២-០២-១៩៩៩ | -អនុក្រឹត្យលេខ ៤២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៦៧ |
| ២៣-០២-១៩៩៩ | -អនុក្រឹត្យលេខ ៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៦៧ |


### ២- សេចក្តីសំរេច


| | | |
|---|---|---|
| ១៧-០២-១៩៩៩ | -សេចក្តីសំរេចលេខ ១៣ សសរ ស្តីពីការកំណត់តំលៃជាវចរន្តអគ្គិសនីនៅរាជធានីភ្នំពេញ និងខេត្តកណ្តាល | ២៦៨ |
| ១៧-០២-១៩៩៩ | -សេចក្តីសំរេចលេខ ១៤ សសរ ស្តីពីការកំណត់តំលៃជាវចរន្តអគ្គិសនី នៅក្រុងព្រះសីហនុ | ២៧០ |
| ២២-០២-១៩៩៩ | -សេចក្តីសំរេចលេខ ១៥ សសរ ស្តីពីការផ្ទេរភារកិច្ច នៃរាជរដ្ឋាភិបាល | ២៧១ |
| ២២-០២-១៩៩៩ | -សេចក្តីសំរេចលេខ ១៦ សសរ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបី នៃកម្មសិទ្ធិបញ្ញា | ២៧២ |

## ៣-សារាចរ

១៨-០២-១៩៩៩ -សារាចរលេខ ០៣ សរ ស្តីពីការពង្រឹងកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ២៧៣

# III-ការងារបណ្តាក្រសួង

## ១-នីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ប្រកាស

១៧-០២-១៩៩៩ -ប្រកាសលេខ ៥១៥ ពណ.បអព ស្តីពីការកំណត់នីតិវិធីថ្មីសំរាប់ដាក់ពាក្យសុំវិញ្ញាបនបត្រប្រភពដើម លិខិតនាំចេញបណ្តោះអាសន្ន និងទិដ្ឋាការនាំចេញ ២៨០

## ២-នីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

១៧-០២-១៩៩៩ -ប្រកាសលេខ ១៨៧ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុនញូ អូរៀន (ខេមបូឌា) ហ្គារមែន តំណាងដោយលោក **GUO YA HONG** សញ្ជាតិ ចិន បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ នាំចេញ ២៨២
១៨-០២-១៩៩៩ -ប្រកាសលេខ ២០៤ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ខេមបូឌា ដូនណើនីញ៉ុង លីមីធីត តំណាងដោយលោក **WANG YI SHENG** សញ្ជាតិ ចិន បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ២៨៤
១៩-០២-១៩៩៩ -ប្រកាសលេខ ២២៩ ឧក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ទ្រីនុង ហ្គាឈ កូម៉ូរ៉ា ប្គាមិុន អ៊ិនដីស្ទ្រី ខូ... លីមីធីត តំណាងដោយលោក **KARDI KOH** សញ្ជាតិ សិង្ហបុរី បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ២៨៥

## ៣-នីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

### ប្រកាស

១៧-០២-១៩៩៩ -ប្រកាសលេខ១២៨អយក.ប្រក ស្តីពីការបើកវិទ្យាល័យហ៊ុន សែន “ ក្រគរ ” ស្ថិតនៅក្នុង ឃុំក្បាលត្រាច ស្រុក ក្រគរ ខេត្តពោធិសាត់ ២៨៧

១៧-០២-១៩៩៩ -ប្រកាសលេខ១២៨អយក.ប្រក ស្ដីពីការប្ដូរឈ្មោះ អនុវិទ្យាល័យ ដើមឫស ទៅជាអនុវិទ្យាល័យ ហ៊ុន សែន ដើមឫស ស្ថិតនៅក្នុងឃុំ ដើមឫស ស្រុក កណ្ដាលស្ទឹង ខេត្ត កណ្ដាល ២៨៨

២៣-០២-១៩៩៩ -ប្រកាសលេខ ១៣៥ អយក.ប្រក ស្ដីពីការបើកសាលាបឋមសិក្សា " ហ៊ុន សែន- អញ្ចាញ " ២៨៩

## ៨-នីស្ដីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស

១៦-០២-១៩៩៩ -ប្រកាសលេខ ០៥២ បទ.ប្រក ស្ដីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធនាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុ ទូរគមនាគមន៍ និង អាជ្ញាប័ណ្ណ ២៩០

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០២៩៩/៣២

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងឯកឧត្តម **មាស គឹមហេង** ជាអគ្គនាយកអាស៊ាន នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេច តាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ១២ អនក្រ.បក
### ស្តីពីការបង្កើតក្រុមហ៊ុនសំភារៈកសិកម្ម

***

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩

### សំរេច

### ជំពូក ១

### បទបញ្ញត្តិទូទៅ

**មាត្រា ១ .-** ត្រូវបានបង្កើតសហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ ឈ្មោះ **ក្រុមហ៊ុនសំភារៈកសិកម្ម** សរសេរកាត់ " ក ហ ស ក " ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួង

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

- គ ហ ស គ មានទីស្នាក់ការនៅផ្ទះលេខ ៣៩៤, កាច់ជ្រុងមហាវិថីព្រះមុនីវង្ស និងផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។
- គ ហ ស គ ពីជានីតិបុគ្គលប្រកបដោយស្វ័យភាពផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ ។
- គ ហ ស គ ត្រូវស្ថិតនៅក្រោមឥទ្ធិពលបទបញ្ញត្តិនៃអនុក្រឹត្យនេះ ហើយនិងគោរពតាមបទបញ្ញត្តិនៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈព្រមទាំងបទបញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម ។

មាត្រា ២ ._ គ ហ ស គ មានកម្មវត្ថុធ្វើពាណិជ្ជកម្ម សេវាកម្មក្នុងវិស័យសំភារៈកសិកម្ម រួមមាន :

- នាំចូល ទិញ លក់ សំភារៈកសិកម្ម មានជាអាទិ៍ ជីគីមី ថ្នាំកសិកម្ម គ្រាប់ពូជដំណាំ និង ឧបករណ៍ផ្សេងៗទៀត តែលេជាមធ្យោបាយបំរើអោយផលិតកម្មកសិកម្ម
- ទទួលទុកដាក់ជីគីមី និងសំភារៈកសិកម្មដែលជាជំនួយ និងចាត់ចែងធ្វើចរាចរតាមគោលការណ៍របស់ក្រសួងអាណាព្យាបាល ដោយទទួលបានកំរៃសេវាសមស្រប
- គ្រប់គ្រងទិន្នន័យស្ថិតិនៃការនាំចេញ នាំចូល និងចរាចរ មុខទំនិញជាសំភារៈកសិកម្មទូទាំងប្រទេស
- ចូលរួមក្នុងកម្មវិធីបណ្ដុះបណ្ដាល សិក្ខាសាលា និងសន្និសីទ ស្តីពីជីគីមី ថ្នាក់ជាតិ និង អន្តរជាតិ
- ចូលរួម និងសំរបសំរួលក្នុងការស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍ការប្រើប្រាស់សំភារៈកសិកម្ម " ជីគីមី " ។

មាត្រា ៣ ._ គ ហ ស គ ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ :

១- ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២- អនុក្រឹត្យស្តីពីការបង្កើត គ ហ ស គ

៣- លក្ខន្តិកៈ គ ហ ស គ

៤- ច្បាប់ និងបទបញ្ជារបស់ក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

មាត្រា ៤ ._ គ ហ ស គ ត្រូវបង់ពន្ធអាករ ស្របតាមច្បាប់ និងបទបញ្ជាជាធរមាន ។

មាត្រា ៥ ._ ដើមទុនដំបូងនៃ គ ហ ស គ ត្រូវកំណត់ឡើងតាម តុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

- ពេលដែលអនុក្រឹត្យនេះចូលជាធរមាន គ ហ ស គ ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋ លើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៦ ._** បុគ្គលិករបស់ ក ហ ស ក មួយចំនួនត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់ នៃក្រុមហ៊ុនសំភារៈកសិកម្មអជ្ញីម ។

បុគ្គលិករបស់ ក ហ ស ក ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២
## ការដឹកនាំ និងគ្រប់គ្រង

**មាត្រា ៧ ._** ក ហ ស ក ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងទូលំទូលាយដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនៃអនុក្រឹត្យនេះ និងលក្ខន្តិកៈរបស់ខ្លួន ។

- ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

+តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប ជាប្រធាន

+តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប ជាសមាជិក

+តំណាងក្រសួងពាណិជ្ជកម្ម ១រូប ជាសមាជិក

+អគ្គនាយក ក ហ ស ក ១រូប ជាសមាជិក

+តំណាងនិយោជិតរបស់ ក ហ ស ក ១រូប ជាសមាជិកស្វ័យប្រវត្តិ

**មាត្រា ៨ ._** សមាជិកក្រុមប្រឹក្សាភិបាល ជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំពេញការងារយ៉ាងតិច ០៥ ( ប្រាំ ) ឆ្នាំ ឬជាឥស្សរជន ដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យ សំរាប់អាណត្តិ ៣ ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា និងអាចបន្តទៀតបានដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងដែលខ្លួនតំណាងអោយ ។
- តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិត ក ហ ស ក ។

**មាត្រា ៩ ._** ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញដើម្បីសំរេចក្នុងនាមនៃ ក ហ ស ក ក្នុងការរៀបចំលិខិតស្នាម រាល់ឯកសារផ្សេងៗ ទាក់ទងទៅនឹងកម្មវត្ថុ របស់ក្រុមហ៊ុនស្របតាមច្បាប់ជាធរមាន ។

ក្រុមប្រឹក្សាភិបាលមានតួនាទី :

១-ផ្តល់ការយល់ព្រមលើគំរោងផែនការរបស់ក្រុមហ៊ុន ដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ ។

២-វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលអោយបានសមស្របតាមសភាពការណ៍ ។

៣-ផ្តល់ការយល់ព្រមលើតុល្យការ និង គណនីប្រចាំឆ្នាំ និង របាយការណ៍សកម្មភាពរបស់ ក ហ ស ក ។

៤-សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈរបស់ គ ម ស គ ព្រមទាំងលក្ខន្តិកៈបុគ្គលិក និងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់ បុគ្គលិកដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន ។

៥-ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងកិច្ចព្រមព្រៀងដែល គ ម ស គ ជាភាគីស្របតាមលក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦-សំរេចបង្កើត បើក ឬបិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ គ ម ស គ តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧-សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលទ្ធកម្មនៃសហគ្រាសសាធារណៈ ។

មាត្រា ១០ ._ ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍ នៃក្រុមហ៊ុនតាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកចំនួនបីនាក់ យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាក៏ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច ១ ដង ក្នុងរយៈពេល ៣ ខែ ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិក ក្រុមប្រឹក្សាភិបាល ដើម្បីដឹកនាំការប្រជុំ ។
- ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។
- របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូន សមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋ អោយបានយ៉ាងតិច ១០ ថ្ងៃ មុនពេលបើកអង្គប្រជុំ ។
- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចបីនាក់រួមទាំងប្រធានផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ ថ្ងៃ ក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំចាំបាច់ទាមទារកូរ៉ុមទេ ។
- សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១១ ._ សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយដែល ត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា២៤ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

-កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំដែលជ្រើសរើសដោយអគ្គនាយក គ ម ស គ ។

មាត្រា ១២ ._ អគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ ក ហ ស ក លើកលែងតែភារកិច្ចដែលមានចែងក្នុងមាត្រា ៩ និងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា និងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា១៣ ._ ក្រុមប្រឹក្សាភិបាល ត្រូវប្រគល់ជូនអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំក្រុមហ៊ុនស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះអគ្គនាយកត្រូវ ៖

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល និងចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមតំណាក់កាលនីមួយៗ អគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ ក ហ ស ក ។

២-ទទួលដឹកនាំ ក ហ ស ក លើផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងអោយ ក ហ ស ក ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាម ស៊ីវិល រដ្ឋបាល ឬលិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រាបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ ក ហ ស ក ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬច្បាប់ជាធរមាន និងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងអោយ ក ហ ស ក ចំពោះមុខតុលាការ និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់ តវ៉ា ការពារក្តីឲ្យ ក ហ ស ក និងការប្តឹងជំទាស់ផ្សេងៗ ។

៧-កំណត់ថ្លៃទិញ លក់មុខទំនិញដែលស្ថិតក្នុងអាជីវកម្មរបស់ ក ហ ស ក ។

មាត្រា ១៤ ._ លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ព្រមទាំងលាភការ របស់អគ្គនាយកត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៥ ._ ការចុះ និងការអនុវត្តកិច្ចសន្យាដោយ ក ហ ស ក ត្រូវគោរពតាមបែបបទ និងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៦ ._ ក ហ ស ក កាន់កាប់គណនេយ្យរបស់ខ្លួន អោយបានសមស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃ ០១ ខែមករា ហើយបញ្ចប់នៅថ្ងៃ ៣១ ខែធ្នូ នៃឆ្នាំដដែល ។
- តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃ៣០ ខែមីនា នៃឆ្នាំបន្ទាប់ ( ឆ្នាំបិទការិយបរិច្ឆេទ ) ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។
- តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងកំឡុងពេលមិនលើសពី ១៥ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

**មាត្រា ១៧ ._** ស្នងការគណនីត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់អាណត្តិពីរការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

- លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងជំពូកបន្ទុកអាជីវកម្មរបស់ ក ឃ ស ក ។
- ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំ នៃការិយបរិច្ឆេទ មានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដ នៃស្ថានភាពហិរញ្ញវត្ថុរបស់ ក ឃ ស ក ។
- បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការស្នងការគណនីនៃសហគ្រាសសាធារណៈ ។
- ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបានតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៨ ._** រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់ក្រុមហ៊ុន តាមសំណើរបស់អគ្គនាយកហើយបញ្ជូនគំរោងនេះ ដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ ក ឃ ស ក ។

៣- ការប៉ាន់ស្មានថ្លៃទិញ លក់មុខទំនិញដែលស្ថិតក្នុងអាជីវកម្មរបស់ ក ឃ ស ក ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ ក ឃ ស ក ។

**មាត្រា ១៩ ._** ធនធាននៃ ក ឃ ស ក ជាអាទិ៍មាន :

+ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ ( តុល្យការដំបូងនៅពេលបង្កើត ) ។

+ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យបន្ថែម ។

+ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទបានមកពីសកម្មភាពរបស់ គ ង ស គ ។

+ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ គ ង ស គ ។

+ប្រាក់ដែលរដ្ឋខ្ចីផ្តល់ឲ្យ និងប្រាក់អំណោយផ្សេងៗ ។

**មាត្រា ២០ ._** ចំណាយនៃ គ ង ស គ រួមមាន :

+ចំណាយប្រព្រឹត្តិសំរាប់ដំណើរការ

+ចំណាយវិនិយោគ

+ចំណាយកសាងសង់

+សងបំណុល

+ចំណាយផ្សេងៗ

**មាត្រា ២១ ._** គ ង ស គ អាចមានគណនី ក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់ចំនូវការរបស់ខ្លួន ។

**មាត្រា ២២ ._** ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រាក់ចំណេញដែល គ ង ស គ ទទួលបានក្រោយពីការទូទាត់ គ្រប់តាមវិធានគណនេយ្យ គ ង ស គ មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យបានសមស្របទៅតាមលក្ខណៈគ្យាប់ ។

**មាត្រា ២៣ ._** រដ្ឋធានាតែចំពោះបំណុលណា ដែលមានការយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា ២៤ ._** រយៈពេល ១៥ថ្ងៃ យ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល គ ង ស គ ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់ក្រុមហ៊ុន ( ដូចមានចែងក្នុងមាត្រា ១៨ )
- របាយការណ៍ស្តីពីសកម្មភាព-តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ គ ង ស គ
- របាយការណ៍របស់ស្នងការគណនី ។

**មាត្រា ២៥ ._** ត្រូវដាក់ឲ្យនៅអម គ ង ស គ នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុច នៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយ អនុលោមតាមបទបញ្ញានៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

ជំពូក ៥

អវសានបញ្ញត្តិ

**មាត្រា ២៦ .**_ បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៧ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគ្គនាយកក្រុមហ៊ុនសំភារៈកសិកម្ម ត្រូវអនុវត្តនូវអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៣៧ អនក្រ.តត**

**ស្តីពីការកែសំរួលរចនាសម្ព័ន្ធចាត់តាំងក្រសួងការពារជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៨៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- យោងព្រះរាជក្រឹត្យ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការដ្ឋាននៃកងទ័ពជាតិកម្ពុជា
- យោងអនុក្រឹត្យលេខ ១០ អនក្រ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតខុទ្ទកាល័យស៊ីវិល ខុទ្ទកាល័យយោធា និង នាយកដ្ឋានចំណុះក្រសួងការពារជាតិ
- ផ្អែកតាមតំរូវការនៃការរៀបចំ គ្រប់គ្រង និង ការប្រព្រឹត្តិទៅរបស់ក្រសួងការពារជាតិឲ្យបានសមស្រប
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១ .-** ត្រូវបានកែសំរួលតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងក្រសួងការពារជាតិសំដៅបង្កើនសមត្ថភាពដឹកនាំ និង គ្រប់គ្រងលើវិស័យការពារជាតិ និងធានាគ្រប់គ្រងផ្គត់ផ្គង់សំភារៈគ្រឿងបំពាក់ ថវិកាដល់កងយោធពលខេមរភូមិន្ទ ។

**មាត្រា ២ .-** តួនាទី ភារកិច្ច របស់ក្រសួងការពារជាតិ រួមមាន ៖

- ដឹកនាំគ្រប់គ្រងលើវិស័យការពារជាតិ ។
- ផ្គត់ផ្គង់សំភារៈ គ្រឿងបំពាក់ ថវិកា សំរាប់ផ្គត់ផ្គង់ជីវភាពគ្រប់បែបយ៉ាងចំពោះបុគ្គលិកកងទ័ពទាំងមូល ។
- អនុវត្តន៍សន្ធិសញ្ញាសហប្រតិបត្តិការ ខាងវិស័យយោធាជាមួយបណ្តាប្រទេសដែលមានការព្រមព្រៀងនឹងគ្នា ។
- ចាត់តាំងខ្សែរយៈធានា ត្រួតពិនិត្យតាមដានរាល់ការអនុវត្តន៍លើការប្រើប្រាស់សំភារៈគ្រឿងបំពាក់ និង ថវិកា ទូទាំងកងយោធពលខេមរភូមិន្ទ ។

**មាត្រា ៣ .-** រចនាសម្ព័ន្ធចាត់តាំងទីស្តីការ ក្រសួងការពារជាតិត្រូវបានកែសំរួលបង្កើតជាស្ថាប័នដូចខាងក្រោម និងស្ថិតនៅក្រោមការគ្រប់គ្រង ដឹកនាំ បញ្ជាផ្ទាល់របស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ គឺ :

**ក- នាយកដ្ឋាន និង ស្ថាប័នចំណុះ :**

- ខុទ្ទកាល័យ
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋាននយោបាយ និង ផែនការ
- នាយកដ្ឋានភូមិសាស្ត្រ
- អធិការកិច្ច
- អយ្យការ
- តុលាការ

**ខ- អគ្គនាយកដ្ឋានចំណុះ :**

**១-អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ រួមមាន :**

- នាយកដ្ឋានផ្គត់ផ្គង់
- នាយកដ្ឋានហិរញ្ញវត្ថុ
- នាយកដ្ឋានសុខាភិបាល
- នាយកដ្ឋានប្រេងឥន្ធនៈ

**២-អគ្គនាយកដ្ឋានយោធសេវា រួមមាន :**

- នាយកដ្ឋានទាក់ទងអន្តរជាតិ
- នាយកដ្ឋានកិច្ចការយោធាស៊ីវិល
- នាយកដ្ឋានសោធននិវត្តន៍

- នាយកដ្ឋានហេសនាសាធារណៈ

៣-អគ្គនាយកដ្ឋានសម្ភារៈ បច្ចេកទេស រួមមាន :

- នាយកដ្ឋានបំពាក់
- នាយកដ្ឋានបច្ចេកទេស
- នាយកដ្ឋានវិស្វកម្ម
- នាយកដ្ឋានឃ្លាំងសារ

ក្រៅពីនេះក្រសួងការពារជាតិ អាចមានទីប្រឹក្សាមួយចំនួនទៀត ដើម្បីជាជំនួយការងារ ។

**មាត្រា ៤ .**_ ប្រគល់ភារកិច្ចជូនសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ធ្វើការរៀបចំ និង កែសំរួលរចនាសម្ព័ន្ធ និងក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋាន ព្រមទាំងបណ្តានាយកដ្ឋាន និង ស្ថាប័នចំណុះ ។

**មាត្រា ៥ .**_ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ .**_ ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៣៨ អនក្រ.តត

## ស្តីពីការផ្លាស់មន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ ._ ផ្លាស់លោក ហាទ ម៉ុនស៊ៃ បច្ចុប្បន្នអគ្គទីប្រឹក្សានិងជាភារៈធារីស្ថានទូតកម្ពុជា ប្រចាំសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ សាធារណរដ្ឋហុងគ្រី សាធារណរដ្ឋឆេក្ក និង សាធារណរដ្ឋស្លូវ៉ាគី អោយចូលមកបំរើការងារក្នុងប្រទេសវិញ ដោយរួចប់អាណត្តិ ។

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ ._ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៣៩ អនក្រ.តត

## ស្តីពីការ ជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

សំរេច

មាត្រា ១ ._ ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកឧកញ៉ា **ម៉ុង ឫទ្ធី** នាយកក្រុមហ៊ុន សំណង់ក្នុងវត្ត ដែលបានជួយសាងសង់ អាគាររដ្ឋបាលចំនួន ០៣ កន្លែងជូនក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២ ._ ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៨០ អនក្រ.តត

## ស្តីពីការ ជូនមេដាយការងារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការ ប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់កងវរសេនាតូចលេខ ២

## សំរេច

មាត្រា ១ ._ ត្រូវប្រគល់មេដាយការងារជូនចំពោះ នាយទាហាន និងមន្ត្រីរាជការ ចំនួន ១៨០ រូប ដែលមានរាយ នាមជូនដូចខាងក្រោម ៖

ក-មេបាយ មាសការខារ ១០២ រូប

| | |
|---|---|
| ១-នាយឧត្តមសេនីយ៍ផ្កាយមាស ៤ កែ គឹមយ៉ាន | ២១-ឧត្តមសេនីយ៍ត្រី សៅ សុខា |
| ២-ឯកឧត្តម លឹម គៀនហោ | ២២- - ឈិន ច័ន្ទពណ៌ |
| ៣- - ឯម សំអាន | ២៣- - ខឹម ជាសាខឿន |
| ៤- - អ៊ុក ពរេន | ២៤- - កែវ ពង្ស |
| ៥- - ផាន់ ងួន | ២៥- - ចាប ភក្តី |
| ៦-ឧត្តមសេនីយ៍ឯក ប៉ុល សារឿន | ២៦- - ម៉ៅ សុផាន់ |
| ៧-ឧត្តមសេនីយ៍ មាស សុភា | ២៧- - ហ៊ីង ប៊ុនហៀង |
| ៨-ឧត្តមសេនីយ៍ ខឹម សោភ័ណ្ឌ | ២៨- - ហ៊ុយ ពិសិដ្ឋ |
| ៩- - ហុក ឡុងឌី | ២៩- - ស៊ារិទ្ធ ស៊ីនិត |
| ១០- - គន់ គឹម | ៣០- - អ៊ុក ជឿន |
| ១១-ឧត្តមសេនីយ៍ទោ មល់ រឿប | ៣១- - ឡាញ់ កៅ |
| ១២- - យូ ស៊ុនឡុង | ៣២- - ប៉ែន ហត |
| ១៣- - ស៊ារិទ្ធ ឌី | ៣៣- - នេត្រ សារឿន |
| ១៤- - ដាំ វុទ្ធី | ៣៤- - ចក់ ឡេង |
| ១៥- - គៀង សាវុធ | ៣៥- - ពិន ណារិទ្ធ |
| ១៦- - ព្រហ្ម ឌិន | ៣៦-ឯកឧត្តម ឌិម យិនទៀង |
| ១៧- - ម៉ឹង សំផន . | ៣៧- - ងួន ប៉ែន |
| ១៨- - ស៊ុំ សំណាង | ៣៨- - ហូ សុទ្ធី |
| ១៩- - ចៅ ភិរុណ | ៣៩- - មុត ខៀវ |
| ២០- - ហេង ប៊ូរិន | ៤០- - ប្រាក់ បាណ្ណឌី |

៤១- - ប្រាក់ សុខុន

៤២- - ឃី ដន

៤៣- - ឈឹម ឈាងសែ

៤៤- - ណើប សុវត្ថិ

៤៥- - ឈុន សារុន

៤៦- ឯកឧត្តម ទេព ងន

៤៧- វរៈសេនីយ៍ឯក ប្រាក់ ផល្លី

៤៨- - ពៅ ស៊ីថា ងន

៤៩- - អន កំសត់

៥០- - សុខ សៀន

៥១- - តូ ស៊ុន

៥២- - ម៉ក់ ចាន់សុខន

៥២- - ម៉ក់ ចាន់សុខន

៥៣- - ជួង សុវណ្ណ

៥៤- - សុខ ឃាង

៥៥- - ឈា ស៊ីផារ៉ា

៥៦- - រៀម ទិត្យ

៥៧- - គង់ សារ៉ាន់

៥៨- វរៈសេនីយ៍ឯក ឯក គ្រឹត្យ

៥៩- - តុប ចន

៦០- - ប៊ិត គីមឡុង

៦១- - ឈើ គីមឡុង

៦២- - មុំ សាមាន

៦៣- - ចៅ តុល

៦៤- - ស៊ុខ យាន

៦៥- - សុខ តារុណ្ណ

៦៦- - ហេង សារឿន

៦៧- - សុខ សុខៈ

៦៨- - ខៀង សារុន

៦៩- វរសេនីយ៍ឯក គង់ វណ្ណា

៧០- - នួន ណារិទ្ធ

៧១- - យេង់ សារិទ្ធ

៧២- - សុខ សុវណ្ណ

៧៣- - សោម ដន

៧៤- - ហែម ថា

៧៥- - សេង សុង

៧៦- - ស្រី សុផល

៧៧- - អ៊ុង សារិទ្ធ

៧៨- លោក ម៉ក់ សំអឿន

៧៩- លោក នួន ផា
៨០- - ហើម គឹមហុក
៨១- វរសេនីយ៍ទោ ហែម រិន
៨៣- - ប៊ូ ខេន
៨៤- - ឡេង សំអឿន
៨៥- - គន់ ហេង
៨៦- វរៈសេនីយ៍ទោ ប៊ុច សួឌី
៨៧- - រឿង វុទ្ធី
៨៨- - អ៊ឹង ចំណាន
៨៩- - ហ៊ឹម រិន
៩០- - រស់ សំអុល
៩១- - ស៊ឹម សុទ្ធ
៩២- វរៈសេនីយ៍ទោ ប៉េត ស៊ីថា
៩៣- - កើត ចន
៩៤- - ជា លន
៩៥- - គង់ ធារី
៩៦- - យ៉ាត វិត
៩៧- - ទុន សុខុន
៩៨- - ឌិន ទី
៩៩- - កែវ សុខគី
១០០- - លីវ វណ្ណថុល
១០១- - អ៊ុំ សំអាត
១០២- - ជា សារិន

ខ-មេដាយប្រាក់ការងារ ៨៣ រូប

១- លោក មៃឃែល ថាច់នេន
២- - សុង ម៉េងគង់
៣- - គួច ណាងហួ
៤- - សៀក ឡេង
៥- - ឡេង ម៉េង
៦-វរសេនីយ៍ទោ តូច តារ៉ា
៧- - ប្រាក់ សិទ្ធ
៨- - ភួង ស៊ីភិន
៩- លោក មុំ ម៉ើរ
១០- - ខាត់ សំប៊ិន
១១- - ប៉ែន ពាន់
១២-វរសេនីយ៍ទោ ថាន់ សារី
១៣- - ហែម ឫទ្ធី
១៤- - យ៉ាត ទូច
១៥- - ពេង សុខា
១៦- - នន្ទ និន្ទ

១៧-វរៈសេនីយ៍ទោ ប្រាជ្ញ សុផល
១៨- - ធី សម្បត្តិ
១៩- - ឈឹម វាសនា
២០- - ចាន់ តាំ
២១- - ចាន់ ញាំ
២២- លោក ព្រហ្ម ពន្លឺ
២៣-វរសេនីយ៍ទោ អ៊ុក អ៊ុន
២៤- - ទិត្យ យ៉ន
២៥- - កេត សំអាត
២៦- - មាស សកគន
២៧- - ព្រាប លីណា
២៨- - ហៃល ហាន
៣០- - មាស សុខុន
៣១-វរៈសេនីយ៍ត្រី ឃួន សាមិត្ត
៣២- - ធាយ សារ៉េត
៣៣- - នូវ សារ៉ុន
៣៤- វរសេនីយ៍ទោ សុខ សំរ៉ាង
៣៥- - កេត សំអាត
៣៦- - មាស យ័ន្ត
៣៧- - ពេជ្រ សុវណ្ណ
៣៨- - ម៉ុញ ពិសិដ្ឋ
៣៩- - ស៊ុន ចាន់សុភី
៤០- - យស់ ស្ការិន
៤១- - ប៉ោម កាន
៤២- - ឯល សំនាង
៤៣- - គួន ផល

គ-មេធាវីសរីរិទ្ធការខោរ ៣៥ រូប

១-វរសេនីយ៍ទោ មៃ សារឿន
២-វរសេនីយ៍ត្រី ស៊ឹម ផាន
៣- - លីន សុផល
៤- - អ៊ុក សំ
៥- - ងួន ហុង
៦- - តេង សុខុម
៧- - អន ណាត្រី
៨-វរៈសេនីយ៍ត្រី ជិម ខេមរ៉ា
៩- - គឹម គិច
១០- - ងី សំណាង
១១- - សុខ សុន
១២- - ឈឹម សារឿន
១៣- - សុខ គឹមអេង
១៤- - ស៊ឹម សុគន្ធា

| | | | |
|---|---|---|---|
| ១៥-វរៈសេនីយ៍ | ម៉ម តុលា | ២៦-វរៈសេនីយ៍ត្រី | នួន ស៊ីណា |
| ១៦- - | ឯលេ វណ្ណធន | ២៧- - | ស៊ុំ ចំរើន |
| ១៧- - | យេង់ សាវឿន | ២៨- - | សៀម សំអឿន |
| ១៨- - | សរ សារ៉ន | ២៩- - | បេន ជំនិត |
| ១៩- វរសេនីយ៍ត្រី | សុខ សារុំ | ៣០- - | គឹម ពៅ |
| ២០- - | ប្រុញ សត្ថិម៉ា | ៣១- - | ញ៉ាន សុជាត្រា |
| ២១- - | ធឹង យ៉ាជ | ៣២- - | ម៉ៅ វណ្ណៈ |
| ២២- - | នួ ណាវណ្ណដា | ៣៣- - | វង្ស សុវណ្ណ |
| ២៣- - | នួ ប្រុសពៅ | ៣៤- - | សុខ សាវឿន |
| ២៤- - | ព្រហ្ម វណ្ណី | ៣៥- អនុសេនីយ៍ឯក | ប៉ែន សុវណ្ណ |
| ២៥- - | អ៊ុក ធួ | | |

**មាត្រា ២ .-** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តន៍អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤១ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

សំរេច

មាត្រា ១ ._ តែងតាំងលោក ហ៊ី ម៉ុនគីម ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង- ស្ថាប័នពាក់ព័ន្ធ និងលោក ហ៊ី ម៉ុនគីម ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ៤២ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

សំរេច

មាត្រា ១ ._ តែងតាំងលោក ផាន់ សាតឿន បច្ចុប្បន្នជាប្រធានស្តីទី នៃនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង- ស្ថាប័នពាក់ព័ន្ធ និងលោក **ផាន់ សាឆឿន** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤៣ អនក្រ.តត

## ស្តីពីការ ជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សំរេច

**មាត្រា ១ ._** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនចំពោះក្រុមហ៊ុន ទូរគមនាគមន៍ នៃសាធារណរដ្ឋកូរ៉េ និងតំណាង ដែលបានធ្វើអំណោយជាសំភារៈ បរិក្ខារ ទូរគមនាគមន៍ ដែលមានតម្លៃសរុបចំនួន ១.២៩៥.៦០៨,៥៧ ដុល្លារអាមេរិក ជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍កម្ពុជា ដូចមានរាយនាមខាងក្រោមនេះ ÷

១-ក្រុមហ៊ុន KOREA TELECOM

២-ក្រុមហ៊ុន LG INFORMATION AND COMMUNICATION LTD

៣- Mr. MOON YANG HWAN, KOREA TELECOM

៤- Mr. JANG IN YONG

៥- Mr. PARK KYUNG TAI, KOREA EMBASSADOR TO KINGDOM OF CAMBODIA

មាត្រា ២ ._ ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយបានទទួលផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

**សេចក្តីសំរេចលេខ ១៣ សសរ**

**ស្តីពីការកំណត់តំលៃជាវចរន្តអគ្គិសនី**

**នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការតែងតាំងរាជរដ្ឋាភិបាលថ្មី
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសំណើរួមរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- យោងស្មារតីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៩

**សំរេច**

មាត្រា ១ ._ កំណត់តំលៃជាវចរន្តអគ្គិសនី នៅរាជធានីភ្នំពេញ និងនៅខេត្តកណ្តាលសំរាប់អតិថិជនទាំងអស់ទៅតាមប្រភេទ និងថ្លៃដូចខាងក្រោម :

១-អតិថិជន លំនៅដ្ឋាន : តំលៃលក់ ៣៥០រៀល ក្នុង០១គីឡូវ៉ាត់ម៉ោង ត្រូវបានរក្សាទុកដដែល។

២-អតិថិជនឧស្សាហកម្ម និងសិប្បកម្ម : តំលៃលក់ ១៧ សេនដុល្លារអាមេរិក ក្នុង០១គីឡូវ៉ាត់ម៉ោង ។

៣-អតិថិជន ពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្មផ្សេងៗ ៖ តំលៃលក់ ១៧ សេនដុល្លារអាមេរិក ក្នុង ០១ គីឡូវ៉ាត់ម៉ោង ។

៤-អតិថិជនស្ថានទូត សណ្ឋាគារ ផ្ទះជួលអោយជនបរទេស ៖ តំលៃលក់ ២១សេនដុល្លារអាមេរិក ក្នុង ០១គីឡូវ៉ាត់ម៉ោង ។

៥-អតិថិជន អង្គភាពរដ្ឋបាលបុព្វហេតុ ៖ តំលៃលក់ ៧០០ រៀល ក្នុង ០១ គីឡូវ៉ាត់ម៉ោង ។

មាត្រា ២ ._ សេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ស្តីពីការកំណត់ថ្លៃជាវអគ្គិសនីពីមុន និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ ._ ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីរដ្ឋលេខាធិការនៃក្រសួង - ស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ អភិបាលខេត្តកណ្តាល និងអគ្គិសនីកម្ពុជា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ១៤ សសរ

## ស្តីពីការកំណត់តំលៃជាវចរន្តអគ្គិសនី

## នៅ ក្រុងព្រះសីហនុ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការតែងតាំងរាជរដ្ឋាភិបាលថ្មី
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញសំណើរួមរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- យោងស្មារតីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៩

**សំរេច**

ប្រការ ១ : កំណត់តំលៃជាវចរន្តអគ្គិសនី នៅក្រុងព្រះសីហនុ សំរាប់អតិថិជនទាំងអស់ទៅតាមប្រភេទ និងថ្លៃដូចខាងក្រោម :

១-អតិថិជន លំនៅដ្ឋាន : តំលៃលក់ ៥០០រៀល ក្នុង០១គីឡូវ៉ាត់ម៉ោង ត្រូវបានរក្សាទុកដដែល។

២-អតិថិជនឧស្សាហកម្ម និងសិប្បកម្ម : តំលៃលក់ ១៧,៥០ សេនដុល្លារអាមេរិក ក្នុង០១ គីឡូវ៉ាត់ ម៉ោង ។

៣-អតិថិជន ពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្មផ្សេងៗ : តំលៃលក់ ១៩,៥០ សេនដុល្លារអាមេរិក ក្នុង ០១ គីឡូវ៉ាត់ម៉ោង ។

៤-អតិថិជនស្ថានទូត សណ្ឋាគារ ផ្ទះជួលអោយជនបរទេស : តំលៃលក់ ២០ សេនដុល្លារអាមេរិក ក្នុង ០១គីឡូវ៉ាត់ម៉ោង ។

៥-អតិថិនជន អង្គភាពរដ្ឋបាលបុព្វហេតុ : តំលៃលក់ ២០ សេនដុល្លារអាមេរិក ក្នុង ០១ គីឡូវ៉ាត់ ម៉ោង ។

ប្រការ ២ : សេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ស្តីពីការកំណត់ថ្លៃជាវអគ្គិសនីពីមុន និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង - ស្ថាប័នពាក់ព័ន្ធ អភិបាលក្រុងព្រះសីហនុ និងអគ្គិសនីកម្ពុជាមានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពី ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**សេចក្តីសំរេចលេខ ១៥ សសរ**

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩

**ស្តីពីការផ្ទេរភារកិច្ច នៃរាជរដ្ឋាភិបាល**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និង ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាល ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចនិងចូលរួមប្រជុំពិគ្រោះយោបល់ស្តីពីកម្ពុជា នៃបណ្តាប្រទេសផ្តល់ជំនួយ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ចាប់ពីថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ១៩៩៩ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## សេចក្តីសំរេចលេខ ១៦ សសរ

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩

### ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងផ្នែក
### ទាំងបីនៃកម្មសិទ្ធិបញ្ញា

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងកិច្ចព្រមព្រៀង ស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និង កម្មសិទ្ធិបញ្ញា រវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៦
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- យោងតាមស្មារតីអង្គប្រជុំអន្តរក្រសួង នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៩

**សំរេច**

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបី នៃកម្មសិទ្ធិបញ្ញា ដែលមានសមាសភាពដូចខាងក្រោម :

- ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ប្រធាន
- ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អនុប្រធាន
- ឯកឧត្តម តំណាង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- ឯកឧត្តម តំណាង ក្រសួងពត៌មាន សមាជិក

**ប្រការ ២ :** គណៈកម្មការគ្រប់គ្រងផ្នែកទាំងបី នៃកម្មសិទ្ធិបញ្ញា មានភារកិច្ចដូចតទៅ ៖

- ជំរុញការរៀបចំសេចក្តីព្រាងច្បាប់នានា ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍កិច្ចព្រមព្រៀង ស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និង កម្មសិទ្ធិបញ្ញា រវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក និងកិច្ចព្រមព្រៀងនានា រវាងព្រះរាជាណាចក្រកម្ពុជា និងអង្គការប្រទេសនៃសមាគមអាស៊ាន។
- សំរបសំរួលអោយមានភាពរលូនលើរាល់ការងារ ដែលទាក់ទិនដល់កម្មសិទ្ធិបញ្ញា រវាងក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងពត៌មាន និង ក្រសួងស្ថាប័នផ្សេងៗទៀត ដែលមានការពាក់ព័ន្ធ ។
- សំរបសំរួល និង ទទួលជំនួយនានាពីសហគមន៍អន្តរជាតិ លើវិស័យកម្មសិទ្ធិបញ្ញា ។
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល តាមតំរោវការពេលនីមួយៗ ។

**ប្រការ ៣ :** គណៈកម្មការនេះ មានលេខាធិការដ្ឋានមួយ សំរាប់ជួយការងារដែលមានសមាសភាពដូចខាងក្រោម :

- ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ប្រធាន
- តំណាង ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល សមាជិក
- តំណាង ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- តំណាង ក្រសួង ពត៌មាន សមាជិក

លេខាធិការដ្ឋាននេះ មានទីតាំង និងប្រើប្រាស់មន្ត្រីជំនួយការមួយចំនួនទៀត តាមការចាំបាច់ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៤ :** សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន

-គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ដើម្បីសំរួលការងារ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ

នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ១ និង ប្រការ៣ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

## ៣-សារាចរ

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩

### សារាចរលេខ ០៣ សរ

### ស្តីពីការពង្រឹងកិច្ចការពារសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

***

ក្រោយពីការបោះឆ្នោតជាសកលប្រកបដោយជោគជ័យនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ រហូតមកដល់បច្ចុប្បន្ននេះ ការងារពង្រឹងកិច្ចការពារសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ ធានាបានក្នុងការបំរើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ រួមចំណែកដល់កិច្ចការពារប្រទេសជាតិ ការពារសមិទ្ធផល នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ការពាររដ្ឋធម្មនុញ្ញ និងសមិទ្ធផលនានា ដែលប្រសូត្រចេញពីលទ្ធផល នៃការបោះឆ្នោតថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ ។

ក្នុងការអនុវត្តន៍បេសកកម្មដ៏ឧត្តុង្គឧត្តមនេះ រាជរដ្ឋាភិបាលបានពិនិត្យឃើញនូវចំណុចអសកម្មមួយចំនួនជុំវិញការងារនេះដែលសំខាន់ គឺមិនទាន់ក្លាយទៅជាចលនាភ្ញាក់រលឹកសហការព្រមៗ គ្នារវាងភ្នាក់ងារសន្តិសុខសណ្តាប់ធ្នាប់ មន្ត្រីរាជការ និង ប្រជារាស្ត្រនៅឡើយ ដូចជាអំពើតក់ប្លន់ប្រដាប់អាវុធ ការធ្វើមនុស្សឃាត ការចាប់ជំរិតទារប្រាក់ ការលួចឆក់ ការលួចវត្ថុបុរាណ ការលក់ដូរសំភារៈបរិក្ខារសឹក ការប្រើប្រាស់អាវុធជាតិផ្ទុះខុសច្បាប់ ការគ្រប់គ្រងយានយន្តគ្រប់ប្រភេទលើផ្លូវសាធារណៈ ការបង្ការគ្រោះថ្នាក់អគ្គីភ័យ ការគ្រប់គ្រងស្ថិតិប្រជារាស្ត្រមិនទាន់បានច្បាស់លាស់ ការទប់ស្កាត់សំណង់អនាធិបតេយ្យ ការបង្កាំបទល្បែងស៊ីសងខុសច្បាប់ ពេស្យាចារ ការជួញដូរស្ត្រី និង កុមារក្រុមជនពាលអាវាំសែរ ការផ្សព្វផ្សាយវប្បធម៌អាសអាភាស ការរត់ពន្ធគ្រឿងញៀន ចរាចរប្រាក់ក្លែងក្លាយ ការគេងយកប្រាក់ និង ការលក់ដូរគ្រឿងស្រវឹង មានជាតិពុល ការថែរក្សាអនាម័យសាធារណៈ ។ ល ។ ហេតុបច្ច័យទាំងអស់នេះហើយដែលជះឥទ្ធិពលមិនល្អដល់សន្តិសុខសាធារណៈ ដល់ផ្លូវចិត្ត និង ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ ពិសេសនៅរាជធានីភ្នំពេញ និង ខេត្ត - ក្រុង មួយចំនួន ។ ដោយឡែកក៏នៅមានប្រភេទជនឱកាសនិយមមួយក្តាប់តូច ដែលមានគិតដល់ផលប្រយោជន៍ជាតិជាធំ មិនគិតពីភាពក្រីក្រខ្វះខាតរបស់ប្រជារាស្ត្រ បានញុះញង់ឆ្លៀតឱកាស

យកចំណោញផ្ទៃកនយោបាយរួមបង្កទៅជាចំណោទយ៉ាងស្មុគស្មាញ ហើយមានពេលខ្លះបានធ្វើអោយស្ថានការណ៍សន្តិសុខស្ថិតក្នុងភាពតឹងតែងទៀតផង ។

ចំពោះមុខសភាពការណ៍នេះ ការពង្រឹងកិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ គឺជាភារកិច្ចចាំបាច់ និង បន្ទាន់បំផុតរបស់កងកម្លាំងមានសមត្ថកិច្ច អាជ្ញាធរដែនដី មន្ត្រីរាជការ និងប្រជារាស្ត្រទាំងមូល ។ ដើម្បីសំរេចបាននូវគោលដៅនេះរាជរដ្ឋាភិបាលសូមដាក់ចេញនូវគោលការណ៍ណែនាំដូចតទៅ :

**I–អំពីគោលការណ៍រួម**

១-ពង្រឹងកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ដើម្បីបំរើដល់កិច្ចការស្តារ កសាង និង អភិវឌ្ឍន៍សេដ្ឋកិច្ចរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់ប្រជារាស្ត្រ និង កិត្យានុភាពរបស់ប្រទេសជាតិ ។

២-ពង្រឹងប្រព័ន្ធគ្រប់គ្រងសង្គម បង្កើនការអប់រំសីលធម៌សង្គម លុបបំបាត់ជាបណ្តើរៗវប្បធម៌ពាលាអាវ៉ាសែ ជំរុញអោយមានការអនុវត្តន៍គោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និង ការវិនិច្ឆ័យច្បាស់លាស់ដាច់ខាតដោយមិនរើសមុខ ។

៣-សំដៅកាត់បន្ថយបទល្មើសផ្សេងៗ អោយស្ថិតនៅក្នុងកំរិតទាបបំផុតព្រមទាំងរៀបចំឡើងវិញនូវសណ្តាប់ធ្នាប់សាធារណៈទូទាំងប្រទេសអោយមានរបៀបរៀបរយ មានសីលធម៌ មានអរិយធម៌ និងពង្រឹងប្រពៃណី សេចក្តីថ្លៃថ្នូររបស់ប្រជាជាតិខ្មែរ ។

៤-ត្រូវមានកិច្ចសហប្រតិបត្តិការយ៉ាងទូលំទូលាយ និង ស្និទ្ធស្នាលរវាងមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និង ប្រជារាស្ត្រក្នុងការពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សង្គម ។ កងកម្លាំងនគរបាលជាតិត្រូវធ្វើជាស្នូលនៃចលនាខាងលើនេះ ។ កងកម្លាំងមានសមត្ថកិច្ចដទៃទៀត មន្ត្រីរាជការត្រូវចូលរួមយ៉ាងសកម្ម និងត្រូវខិតខំលុបបំបាត់អោយបាននូវភាពអសកម្មលើប្រជារាស្ត្រ ។

**II- អំពីវិធានការជាក់ស្តែង**

១-ចាត់វិធានការបង្ការ និង បង្ក្រាបនូវអំពើឧក្រិដ្ឋកម្មដែលអាចកើតមាននៅតាមមូលដ្ឋានតាមដងផ្លូវជាតិ ផ្លូវទឹក ។ ក្រសួងមហាផ្ទៃត្រូវពិចារណាកសាងគោលការណ៍រួមមួយ ដើម្បីណែនាំអំពីការងារ ការពារសន្តិសុខនៅតាមភូមិ ឃុំ ទូទាំងប្រទេស ។

២-រៀបចំវិធានការ និង ធ្វើសកម្មភាពទប់ស្កាត់ និង ប្រឆាំងចំពោះអំពើភេរវកម្ម នយោបាយ ភេរវកម្មសេដ្ឋកិច្ច ភេរវកម្មសង្គមស្របគ្នានឹងការយកចិត្តទុកដាក់ប្រយុទ្ធប្រឆាំងនឹង ភេរវកម្មអន្តរជាតិ ។ ប្រមូលផ្តុំពិចារណាកសាងវិធានការជាយុទ្ធសាស្ត្រក្នុងការលុបបំបាត់ការចាប់ មនុស្សជំរិតទារប្រាក់ការប៉ុនប៉ងធ្វើមនុស្សឃាត ឬធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុនក្នុងគោល ដៅធ្វើភេរវកម្ម និង សកម្មភាពទាំងឡាយណាដែលបង្កើតភាពភ័យតក់ស្លុតធ្វើអោយជ្រួលច្របល់ បាត់សណ្តាប់ធ្នាប់សាធារណៈ [illegible]សេរីភាព និង ធ្វើអោយប៉ះពាល់ដល់សេរីភាពនយោបាយ ប៉ះពាល់ដល់

សន្តិសុខ និង សុវត្ថិភាព របស់ភ្ញៀវទេសចរណ៍ ។ ត្រូវប្រើប្រាស់អស់លទ្ធភាពដើម្បី កាត់បន្ថយអោយបានជាអតិបរិមាអំពីល្បួចប្លន់ប្រដាប់អាវុធ ។

ក្រសួងមហាផ្ទៃ ត្រូវរាយការណ៍រៀងរាល់សប្តាហ៍ជូនគណៈរដ្ឋមន្ត្រី អំពីសភាពការណ៍សកម្មភាពចាប់មនុស្សជំរិតយកប្រាក់ដែលកើតមាននៅតាមមូលដ្ឋាននានា ។

៣-ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិត្រូវរៀបចំគោលការណ៍ និង បែបបទអោយបានច្បាស់លាស់ក្នុងការគ្រប់គ្រងការប្រើប្រាស់អាវុធជាតិផ្ទុះ ទាំងក្នុងកងកម្លាំងប្រដាប់អាវុធ ទាំងក្នុងជួរមន្ត្រីរាជការស៊ីវិល និង ក្នុងក្រុមហ៊ុនឯកជននានា ព្រមទាំងប្រជាពលរដ្ឋសាមញ្ញ ។

នៅតាមកងឯកភាព តាមអង្គភាពនានានៃកងកម្លាំងប្រដាប់អាវុធ ត្រូវប្រមូលផ្តុំអាវុធដាក់នៅក្នុងឃ្លាំង ដោយធ្វើបញ្ជីសារពើភ័ណ្ឌច្បាស់លាស់ ហាមមិនអោយយកអាវុធចេញក្រៅកងឯកភាព ឬ អង្គភាព លើកលែងតែមានបេសកកម្ម ឬ បទបញ្ជាពីថ្នាក់លើដែលមានសមត្ថកិច្ច ។

គ្រប់គ្រងអោយបានម៉ត់ចត់ឃ្លាំងរក្សាអាវុធយុទ្ធភ័ណ្ឌរបស់ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ និង គ្រប់គ្រងក្លឹបកីឡាបាញ់ស៊ីប ព្រមទាំងពិចារណាអំពីការអនុញ្ញាតច្បាប់នាំចូលអាវុធឯកជន ដើម្បីឈានទៅលុបបំបាត់ទីផ្សារលក់ដូរអាវុធអនាធិបតេយ្យ ។

ចាត់ការធ្វើអោយបានសំរេចការចុះបញ្ជីគ្រប់គ្រងអាវុធ ដែលកំពុងប្រើប្រាស់នៅក្នុងមូលដ្ឋានអង្គភាព កងឯកភាព ហើយអនុញ្ញាតអោយប្រើប្រាស់តាមការកំណត់ក្នុងអនុក្រឹត្យលេខ ៦២ អនក្រ ចុះថ្ងៃទី ៣១-៧-៩៥ ។ បង្កើនវិធានការគ្រប់គ្រងចំហរដោយចាត់តាំងត្រួតពិនិត្យឆែកឆេរតាមផ្លូវ តាមមធ្យោបាយផ្សេងៗ គួបផ្សំនឹងការចលនាប្រជាពលរដ្ឋ ដើម្បីយកអាវុធមកប្រគល់ជូនអាជ្ញាធរដែនដីថែរក្សាគ្រប់គ្រងវិញ ។

អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ និង អគ្គនាយកដ្ឋាននគរបាលជាតិត្រូវសហការគ្នាដើម្បីកំណត់តំបន់នានាដែលត្រូវប្រមូលអាវុធពីកងជីវពល និង តំបន់ដែលត្រូវរក្សាទុកសិនដោយបញ្ហាសន្តិសុខ និង ខិតខំលុបបំបាត់អោយបានទីផ្សារលក់អាវុធ និង សំភារៈសឹកគ្រប់ប្រភេទ ។

៤-លើកវិធានការទប់ស្កាត់ និង ស្រាវជ្រាវបោសសំអាតឧក្រិដ្ឋជនក្នុងប្រទេស និងបរទេសដែលប្រកបរបរជួញដូរគ្រឿងញៀន ។ អាជ្ញាធរដែនដីត្រូវក្តាប់ភូមិសាស្ត្រដែលមានការដាំដុះ ការផលិតគ្រឿងញៀន ហើយត្រូវតែមានវិធានការបង្ក្រាបលុបបំបាត់អោយបានជាស្ថាពរ ។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវជំរុញការផ្សព្វផ្សាយអប់រំក្នុងស្រទាប់ប្រជាពលរដ្ឋមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ ជាពិសេសក្នុងយុវវ័យ សិស្ស និស្សិត អំពីផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន ដើម្បីចូលរួមទប់ស្កាត់ការប្រើប្រាស់ និង បំបាត់សកម្មភាពជួញដូរគ្រឿងញៀន ។

បង្កើនការត្រួតពិនិត្យតាមរង្គសាល ក្លឹបរាត្រី និង ក្លឹបកំសាន្តផ្សេងៗ បើមានប្រើប្រាស់ ឬ ជួញដូរគ្រឿងញៀន ត្រូវបិទការធ្វើអាជីវកម្មជាស្ថាពរ និង រៀបចំសំណុំរឿងជាបន្ទាន់បញ្ជូនទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ ។

៥-ខិតខំរកអោយឃើញមេក្លោងមេផ្តើមគំនិត និង ជនទុច្ចរិតនៅខាងក្រៅប្រទេសដែលមានទំនាក់ទំនងរកស៊ីជួញដូរកេតនកុមារ ឬ ស្ត្រីភេទដើម្បីយកកម្លាំងពលកម្ម ជាពិសេសការបំពីផ្លូវភេទ ឬ នាំចេញទៅប្រទេសទី២ ។ ក្រសួងមហាផ្ទៃត្រូវសហការជាមួយក្រសួងកិច្ចការនារី និងអតីតយុទ្ធជនអង្គការអន្តរជាតិ អង្គការសិទ្ធិមនុស្ស និង អង្គការមិនមែនរដ្ឋាភិបាលនានាដែល មានការពាក់ព័ន្ធ ដើម្បីបង្ការ និង ទប់ស្កាត់សកម្មភាពទាំងនេះ ។ អាជ្ញាធរដែនដីត្រូវចាត់វិធានការ អោយបានម៉ឺងម៉ាត់ក្នុងការបោសសំអាតបនពេស្យា និង ការចាប់ពង្រត់នារីនិងកុមារ យកមកលក់អោយពួកបនក្នុងរង្វង់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ដោយត្រូវអនុវត្តបទបញ្ញាជាធរមានអោយ ម៉ឺងម៉ាត់តឹងរឹងចំពោះមេបន និង ចំពោះអ្នកចាប់ពង្រត់ ។

៦-អនុវត្តក្នុងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល អំពីការបិទបនល្បែងស៊ីសង កាស៊ីណូ ចំពោះកន្លែងណាដែលត្រូវបានអនុញ្ញាតអោយមានកាស៊ីណូ ត្រូវត្រួតពិនិត្យអោយមានការអនុវត្តន៍ត្រឹមត្រូវតាមលក្ខន្តិកៈ និង កិច្ចសន្យា ដូចជាហាមដាច់ខាតមិនអោយជនជាតិខ្មែរចូលលេងក្នុងបនកាស៊ីណូជាដើម ។

៧-គ្រប់ក្រសួងមានសមត្ថកិច្ច និង អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវចូលរួមទទួលខុសត្រូវថែរក្សាការពារបេតិកភ័ណ្ឌជាតិ ។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សហការជាមួយក្រសួងធម្មការនិងសាសនា និង អាជ្ញាធរដែនដីដើម្បីជំរឿនឡើងវិញ និង ចុះបញ្ជីបដិមាករ វត្ថុបុរាណមានតម្លៃនៅតាមប្រាង្គប្រាសាទ ទីវត្តអារាម ឬ កន្លែងគោរពបូជាផ្សេងៗ នៅទូទាំងប្រទេស ព្រមទាំងកសាងផែនការការពារដើម្បីជៀសវាងការលួចប្លន់ ឬ ជីកកាស់កកាយរកវត្ថុបុរាណ ។

សហការជាមួយអង្គការអន្តរជាតិ និង ស្នងការនគរបាលពិសេសការពារអង្គរ ដើម្បីថែរក្សាការពារតំបន់អង្គរអោយមានសុវត្ថិភាព រាំងអោយបានការលួចជីកកាប់គាស់ ។

៨-បន្តអនុវត្តដោយការទទួលខុសត្រូវខ្ពស់ស្មារតីសារាចរលេខ០៣ស.រ ចុះថ្ងៃទី២៣-០២-៩៦ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើផ្លាកលេខយានយន្តគ្រប់ប្រភេទ ។ ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ត្រូវត្រួតពិនិត្យឡើងវិញអំពីការផ្តល់ផ្លាកលេខយានយន្ត ខ.ម ន.ម ជាលក្ខណៈឯកជនកន្លងមក ហើយត្រូវណែនាំអោយប្រើផ្លាកលេខយានយន្តដែលចេញដោយក្រសួងសាធារណការ និង ដឹកជញ្ជូន ។ ក្នុងករណីមិនព្រមធ្វើតាមការណែនាំ ត្រូវកត់ត្រាយានយន្តនោះបញ្ចូលក្នុងបញ្ជីសារពើភ័ណ្ឌរបស់ក្រសួង ឬ អង្គភាពរដ្ឋ ។

ក្រសួងសាធារណការ និង ដឹកជញ្ជូនត្រូវរៀបចំអោយមានផ្លាកសញ្ញាសំគាល់ច្បាស់លាស់ចំពោះយានយន្តតាក់ស៊ី ដឹកអ្នកដំណើរតូច - ធំ និង នាវាដឹកអ្នកទេសចរណ៍ និង រថយន្តដឹកទំនិញសំភារៈគ្រប់ប្រភេទអោយបានឆាប់រហ័ស ។ ទន្ទឹមនោះត្រូវគ្រប់គ្រងអោយបានមធ្យោបាយយានយន្តគ្រប់ប្រភេទ ដើម្បីធានាភាពស្របច្បាប់ចំពោះការធ្វើចរាចរតាមដងផ្លូវ ។ ត្រូវរៀបចំផ្លាកសញ្ញាចរាចរអោយបានគ្រប់គ្រាន់តាមដងផ្លូវទាំងអស់ ។ ត្រូវផាកពិន័យចំពោះរាល់ករណីល្មើសបទបញ្ជាចរាចរ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហការជាមួយក្រសួងមហាផ្ទៃ ក្រសួងការពារជាតិជាពិសេសអាជ្ញាធរខេត្ត- ក្រុងទាំងអស់ដែលមានព្រំដែនជាប់ប្រទេសថៃ ដើម្បីទប់ស្កាត់ និង ហាមឃាត់ដាច់ខាតចំពោះការនាំចូលរថយន្តចង្កូតស្តាំ ទោះបីតាមរូបភាពណាក៏ដោយ ហើយធ្វើប្រកាសអន្តរក្រសួងរួមមួយ ដើម្បីកំណត់អំពីបទបញ្ញត្តិផ្សេងៗ ស្តីពីការឈប់អោយធ្វើចរាចរនូវយានយន្តចង្កូតស្តាំនេះនៅដើមឆ្នាំ ២០០១ ។

៩-ក្រសួងមហាផ្ទៃត្រូវជំរុញការផ្តល់សៀវភៅស្នាក់នៅ និង សៀវភៅគ្រួសារអោយបានចប់នៅក្នុង ឆមាសទី១ ឆ្នាំ ១៩៩៩ និង ត្រូវជំរុញការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរផងដែរ ។ បង្កើនការ គ្រប់គ្រងសណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួលតាមជំនាញបំរើដល់ការងារសន្តិសុខជាតិ ។

ពង្រឹងការគ្រប់គ្រងដោយម៉ឺងម៉ាត់ប៉ុស្តិ៍ត្រួតពិនិត្យតាមច្រកទ្វារព្រំដែន តាមច្រករបៀងផ្សេងៗសំដៅទប់ស្កាត់អោយបានការជ្រៀតចូលនៃជនអន្តោប្រវេសន៍ខុសច្បាប់ ។ ទន្ទឹមនោះត្រូវចាត់វិធានការម៉ឺងម៉ាត់ ធ្វើសំរង់ស្ថិតិជនបរទេសគ្រប់ប្រភេទ ព្រមទាំងលើកវិធានការជាក់ស្តែងសមស្របតាមច្បាប់អន្តោប្រវេសន៍ ។

បន្តអនុវត្តអោយបានល្អអនុក្រឹត្យលេខ ៤៣ អនក្រ ចុះថ្ងៃទី ១០-៨-៩៤ ស្តីពីសណ្តាប់ធ្នាប់សាធារណៈ នៅរាជធានីភ្នំពេញ និង ខេត្ត - ក្រុង ដោយយកចិត្តទុកដាក់រៀបចំសណ្តាប់ធ្នាប់នៅតាមស្ថានីយ៍រថយន្ត រថភ្លើង ការលក់ដូរអនាធិបតេយ្យ លុបបំបាត់សំណង់អនាធិបតេយ្យ ។ ល ។ ក្នុងករណីចាំបាច់ពីចារណាធ្វើវិសោធនកម្មអនុក្រឹត្យខាងលើនេះ ជាពិសេសចំពោះការផាកពិន័យ ។

អាជ្ញាធរដែនដីត្រូវបន្តលុបបំបាត់ចោលក្រុមត្រួតពិនិត្យអនាធិបតេយ្យតាមផ្លូវគោក ផ្លូវទឹកដែលបាន និង កំពុងប្រព្រឹត្តអំពើអសកម្មនៅទូទាំងប្រទេស ។

ក្រសួងមហាផ្ទៃ សហការជាមួយក្រសួងការពារជាតិរៀបចំលិខិតបទដ្ឋាន ស្តីពីការកំណត់របបប្រើប្រាស់អង្គរក្ស និង គ្រឿងបំពាក់សំរាប់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ប្រទេសជាតិ ឥស្សរជននយោបាយ និងតាមលំដាប់ថ្នាក់ផ្សេងៗទៀត ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ជៀសវាងការបង្កភាពអនាធិបតេយ្យក្នុងការប្រើប្រាស់កងកម្លាំង ការប្រើប្រាស់មធ្យោបាយ និង អាវុធយុទ្ធភ័ណ្ឌ ។

១០-ក្រសួងព័ត៌មាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សហការជាមួយក្រសួងមហាផ្ទៃបង្កើនការត្រួតពិនិត្យអោយបានម៉ឺងម៉ាត់មុននឹងអនុញ្ញាតអោយនាំចូលខ្សែភាពយន្ត ខ្សែវីដេអូ ឬ សិល្បៈវប្បធម៌ផ្សេងៗ ។ ចំពោះការដាក់តាំងលក់ ឬ ការបញ្ចាំងកាសែ្សតវីដេអូដែលគ្មានការត្រួតពិនិត្យបញ្ជាក់ត្រឹមត្រូវពីក្រសួងខាងលើត្រូវធ្វើការព្រមាន ឬ បិទឈប់អោយធ្វើការអាជីវកម្មជាស្ថាពរ ។

ត្រូវមានការកំណត់អាយុសំរាប់ការចូលកំសាន្តផ្សេងៗ នៅតាមរង្គសាល ក្លឹបកំសាន្ត ក្លឹបរាត្រីដើម្បីបង្ការ និង ជៀសវាងនូវការបំពុលវប្បធម៌ពាលាអាក់រអិលចំពោះស្រទាប់យុវវ័យ ។

១១-បង្កើនវិធានការជំនាញដើម្បីតស៊ូប្រឆាំងចំពោះអំពើរទ្ធង្សនាសេដ្ឋកិច្ច ឬ ការធ្វើអោយមានភាពរាំងស្ទះសេដ្ឋកិច្ច ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិ ក្រសួងពាណិជ្ជកម្ម សហការជាមួយក្រសួងមហាផ្ទៃ ដើម្បីលើកវិធានការទប់ស្កាត់ ឬ រកអោយឃើញការលាងលុយក្រខ្វក់ដែលអាចកើតមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ធនាគារជាតិត្រូវពិនិត្យឡើងវិញប្រព័ន្ធគ្រប់គ្រងធនាគារ និងបំពេញបន្ថែមអោយបានគ្រប់គ្រាន់ ជាពិសេសក្នុងការគ្រប់គ្រងធនាគារឯកជន និង ត្រូវមានវិធានការក្នុងការគ្រប់គ្រងការធ្វើចរាចររូបិយប័ណ្ណ ត្បូងថ្មមានតម្លៃអោយបានម៉ឺងម៉ាត់ ។

ត្រូតពិនិត្យអោយបានមឺងម៉ាត់ចំពោះការធ្វើចរាចរទំនិញក្លែងក្លាយ ទំនិញផុតរយៈពេលប្រើប្រាស់ខូចគុណភាព និងក្លែងបន្លំផ្សេងៗ ការនាំចូល ការលក់ឱសថក្លែងក្លាយ និងការរត់ពន្ធឱសថ ។ តាមដានការប្រែប្រួលថ្លៃនៅលើទីផ្សារ ពិសេសទំនិញដែលទាក់ទងដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជារាស្ត្រ មន្ត្រីរាជការ ខិតខំរកអោយឃើញការស្តុកទំនិញដើម្បីតម្លើងថ្លៃ ។ ទប់ស្កាត់បាតុភាពក្នុងការគិបកេងពន្ធដារគ្រប់ប្រភេទអំពើរត់ពន្ធ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សហការជាមួយក្រសួងមហាផ្ទៃ ដើម្បីទប់ស្កាត់អោយបានការធ្វើអាជីវកម្មឈើ កៅស៊ូ នេសាទដោយខុសច្បាប់ ។

ក្រសួងបរិស្ថានសហការជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដើម្បីតាមដានអនុវត្តសេចក្តីប្រកាសលេខ ០១ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ ក៏ដូចជាក្នុងតំបន់ការពារធម្មជាតិ ។

### III-វិធានការចាត់តាំងអនុវត្ត

១-ក្រសួងព័ត៌មាន និង ក្រសួងយុត្តិធម៌ត្រូវរៀបចំកម្មវិធីក្នុងការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋាន ដែលពាក់ព័ន្ធដល់ការការពារសន្តិសុខសាធារណៈ អោយបានជាប្រចាំជូនដល់ប្រជារាស្ត្រ មន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធ ដើម្បីលើកកំពស់ស្មារតីភ្ញាក់រលឹកក្នុងការគោរពប្រតិបត្តិ និងចូលរួមលើកិច្ចការពារសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ ។

បន្តខិតខំធ្វើវិសោធនកម្ម និង កសាងច្បាប់លិខិតបទដ្ឋានថ្មីៗ បន្ថែមទៀតសំរាប់ទ្រទ្រង់ និងគ្រប់គ្រងសង្គមជាតិទៅតាមផ្លូវច្បាប់ស្របតាមសភាពការណ៍ថ្មីរបស់ប្រទេសជាតិ តំបន់ និងពិភពលោក ។ ចំពោះមុខ យកចិត្តទុកដាក់ក្នុងការកសាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់អាវុធ ការផលិត និង ការលក់ដូរឯកសណ្ឋានយោធា នគរបាលជាតិ ច្បាប់ស្តីពីសន្តិសុខជាតិ និងច្បាប់ចរាចរជើងគោក ជើងទឹក ។

២-ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការបើកវគ្គបណ្តុះបណ្តាល ជូនដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធអំពីច្បាប់ លិខិតបទដ្ឋាន មុខជំនាញបច្ចេកទេស នីតិវិធីប្រតិបត្តិការ អប់រំសីលធម៌ សិទ្ធិមនុស្ស និង វិន័យ ដើម្បីអោយសក្តិសមនឹងកិត្តិយសថ្លៃថ្នូរក្នុងកិច្ចការពារមាតុភូមិ ការពារប្រជាពលរដ្ឋ និង កសាងប្រទេសជាតិ ក្នុងគ្រប់កាលៈទេសៈ ។

ត្រូវមានវិធានការយ៉ាងម៉ឺងម៉ាត់ ម៉ត់ចត់ ឆាប់រហ័សចំគោលដៅ ម្ចាស់ការដោះស្រាយបញ្ហាអសកម្ម និង បទល្មើសនានាដែលកើតមាននៅតាមក្រសួង ស្ថាប័ន និង ខេត្ត - ក្រុងនីមួយៗ ។ ប្រើប្រាស់នូវវិធានការច្បាប់ វិធានការរដ្ឋបាល ដើម្បីដាក់វិន័យ និង ផ្តន្ទាទោសចំពោះជនខិលខូចដែលស្ថិតនៅក្នុងកងកម្លាំងប្រដាប់អាវុធជាតិ ក្នុងជួរមន្ត្រីរាជការ ឬ អាជ្ញាធរដែនដី ។

៣-ក្រសួងយុត្តិធម៌ត្រូវមានវិធានការអោយស្ថាប័នតុលាការខេត្ត - ក្រុងជំរុញការកាត់ក្តីសំណុំរឿងព្រហ្មទ័ណ្ឌ និង ត្រូវមានការផ្សព្វផ្សាយជាសាធារណៈជូនដល់សាធារណជនដែលជាវិធានការបង្ការមួយដ៏សំខាន់ ។ ត្រូវធ្វើការណែនាំដល់ស្ថាប័នតុលាការខេត្ត - ក្រុង ក្រោយការកាត់ក្តី និង ចេញសាលក្រមស្ថាពររួចហើយ ចំពោះវត្ថុតាងជាអាវុធយុទ្ធភ័ណ្ឌត្រូវបង្វែរមកអោយក្រសួងមហាផ្ទៃ ឬ ក្រសួងការពារជាតិគ្រប់គ្រងវិញ ។

៤-ក្រសួងអប់រំយុវជននិងកីឡា សហការជាមួយក្រុមប្រឹក្សាអ្នកច្បាប់ និង ក្រសួងយុត្តិធម៌ បញ្ចូលកម្មវិធីបង្រៀនដល់សិស្សានុសិស្ស និង និស្សិតនៅគ្រប់គ្រឹះស្ថានសិក្សាអំពីសីលធម៌ក្នុងការរស់នៅ ច្បាប់ និង លិខិតបទដ្ឋានជាមូលដ្ឋាននានា ។

៥-ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ក្រសួងអភិវឌ្ឍន៍ជនបទផ្អែកតាមសមត្ថកិច្ចនៃក្រសួងនីមួយៗ រួមជាមួយអាជ្ញាធរដែនដី ត្រូវខិតខំបង្កើនកិច្ចសហការជាមួយអង្គការអន្តរជាតិ អង្គការ មិនមែនរដ្ឋាភិបាលខិតខំដោះស្រាយបញ្ហាជនអនាថា ជនពិការ ស្ត្រីមេម៉ាយ កុមារកំព្រា ជនឥតការងារធ្វើព្រមទាំងជួយបណ្តុះបណ្តាលមុខជំនាញ ឯកទេស និង ជួយរកការងារធ្វើជូនដល់ជនទាំងឡាយខាងលើនេះ ។ ខិតខំជំរុញការអភិវឌ្ឍន៍នៅជនបទដើម្បី បង្កលក្ខណៈអោយប្រជារាស្ត្រមានអាជីពគ្រប់ៗគ្នា ដើម្បីប្រកបរបររកស៊ីចិញ្ចឹមជីវិត និង រួមចំណែកលើកកំពស់សេដ្ឋកិច្ចជាតិ ។

៦-រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវរៀបចំដាក់ប្រព័ន្ធត្រួតពិនិត្យកាំរស្មីអ៊ិចនៅក្នុងបន្ទប់ រង់ចាំភ្ញៀវជាន់ខ្ពស់នៅព្រលានយន្តហោះអន្តរជាតិពោធិចិនតុង ដើម្បីត្រួតពិនិត្យវ៉ាន់ឃ្លូវដៃរបស់ភ្ញៀវដែលឆ្លងកាត់ ។ ក្នុងករណីឃើញមានវត្ថុសង្ស័យត្រូវសុំការអនុញ្ញាត ដើម្បីធ្វើការត្រួតពិនិត្យ ទោះបីជាភ្ញៀវខ្មែរនោះកាន់លិខិតឆ្លងដែនការទូតក៏ដោយ លើកលែងតែភ្ញៀវបរទេសដែលកាន់លិខិតឆ្លងដែនការទូត ត្រូវទំនាក់ទំនងជូនពត៌មានមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចាត់វិធានការ ។

៧-ក្រសួងមហាផ្ទៃ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវពិភាក្សាគ្នាដាក់ចេញគោលការណ៍តតិយុត្តសំរាប់គ្រប់គ្រង ត្រួតពិនិត្យប្រព័ន្ធទូរស័ព្ទចល័ត គ្រប់គ្រងរលកធាតុអាកាស និង បែបបទក្នុងការលក់ទូរស័ព្ទចល័ត ដើម្បីរួមចំណែកការពារសន្តិសុខជាតិ ។

៨-ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃត្រូវលើកកំពស់ការគ្រប់គ្រងកងកម្លាំងអោយបានម៉ឺងម៉ាត់ ។ ក្នុងសភាពការណ៍ថ្មីនេះ ត្រូវរៀបចំអោយមានបន្ទាយសំរាប់កងឯកភាពទាំងអស់ ដើម្បីប្រមូលផ្តុំរស់នៅ និង ហាត់ហ្វឹកហ្វឺន ជៀសវាងការដែលកងកម្លាំងទាំងនោះចេញដើរប្រសេចប្រសាច

ក្នុងសង្គមធ្វើអោយបាត់បង់វិន័យ សេចក្តីថ្លៃថ្នូររបស់កងទ័ព និង នគរបាលជាតិ ឬ ក៏ឈានទៅប្រព្រឹត្តនូវបទល្មើសផ្សេងៗ ។

បំពេញបាននូវកិច្ចការទាំងអស់នេះ មិនគ្រាន់តែរួមចំណែកយ៉ាងសំខាន់ដល់កិច្ចការពារសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈប៉ុណ្ណោះទេ ប៉ុន្តែនៅបានពង្រឹងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើការដឹកនាំរបស់រាជរដ្ឋាភិបាល បង្កើតបានជាបុព្វបទសំរាប់នីតិរដ្ឋប្រកបដោយលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សក្នុងព្រះរាជាណាចក្រកម្ពុជានាពេលអនាគត ។

ទទួលបានសារាចរនេះ ក្រសួង ស្ថាប័ន និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវខិតខំផ្សព្វផ្សាយ និង រៀបចំបទដ្ឋានគតិយុត្ត ដើម្បីចាត់ចែងអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់តាមវិធានការជាយុទ្ធសាស្ត្រ និង ជាក់ស្តែងខាងលើអោយមានប្រសិទ្ធភាព រួចរាយការណ៍អំពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាលតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រីតាមការកំណត់នីមួយៗ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# III- ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

### ប្រកាសលេខ ៥១៥ ពណ.បអព

### ស្តីពីការកំណត់និតិវិធីថ្មីសំរាប់ដាក់ពាក្យសុំវិញ្ញាបនបត្រប្រភពដើម លិខិតអនុញ្ញាតនាំចេញបណ្តោះអាសន្ន និងនិដ្ឋាការនាំចេញ

***

### រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម

- បានឃើញអនុក្រឹត្យលេខ ៥៤/អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- បានឃើញការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** កំណត់និតិវិធីថ្មីសំរាប់ដាក់ពាក្យសុំវិញ្ញាបនបត្រប្រភពដើម ( **Certificate of Origin** ) លិខិតអនុញ្ញាតនាំចេញបណ្តោះអាសន្ន ( **Temporary Export Authorization** ) និងទិដ្ឋាការនាំចេញ ( **Export Visa** ) ដោយកំណត់រយៈពេលចាប់ពីពេលទទួលពាក្យរហូតដល់ប្រគល់ពាក្យសុំអោយតាមក្រុមហ៊ុនត្រឹម ២ថ្ងៃធ្វើការពេញ (**Two working days** ) ។

**ប្រការ ២ :** ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវចាត់តាំងមន្ត្រីថ្នាក់អនុប្រធាននាយកដ្ឋាន ១រូប ដើម្បីទទួលភ្ញៀវ ពិនិត្យពាក្យសុំ និងឯកសារយោង ។ នៅពេលពិនិត្យឃើញថាមានឯកសារគ្រប់គ្រាន់សមស្របហើយ មន្ត្រីរូបនោះត្រូវចេញបង្កាន់ដៃមួយអោយអ្នកដាក់ពាក្យសុំដើម្បីបញ្ជាក់ ពិពេលវេលាដែលខ្លួនបានទទួលពាក្យសុំ និងកំណត់ពេលវេលាអោយភ្ញៀវមកទទួលយកសំណុំរឿងវិញនៅ ៤៨ម៉ោង ឬ ២ថ្ងៃ ធ្វើការពេញ ។ បង្កាន់ដៃនោះត្រូវកំណត់ថ្ងៃ ខែ និងម៉ោង ដែលសាមីភ្ញៀវមកទទួលសំណុំរឿងទៅវិញ ។

**ប្រការ ៣ :** រាល់ពាក្យសុំត្រូវឆ្លងបណ្តាលដាប់ថ្នាក់ដែលធ្លាប់មានពីមុន ដោយមានមន្ត្រី **GSP** ២រូបធ្វើជានិរសារយកសំណុំរឿងពីកន្លែងមួយទៅកន្លែងមួយ ។ ត្រូវបានហាមដាច់ខាតនូវការដើរហើររបស់ភ្ញៀវតាមបណ្តានាយកដ្ឋាន ឬ កន្លែងផ្សេងៗដោយរត់ការកាន់សំណុំរឿងដោយផ្ទាល់ខ្លួនឯង ។

**ប្រការ ៤ :** មន្ត្រីទាំងអស់នៅក្នុងនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក៏ដូចជាមន្ត្រីដទៃទៀតនៃក្រសួងពាណិជ្ជកម្មមិនត្រូវតាំងខ្លួនជាអ្នករត់ការអោយភ្ញៀវឡើយ ។ ក្នុងករណីមានភស្តុតាងថាមន្ត្រីណាមួយប្រព្រឹត្តខុសពីបញ្ញត្តិនេះ ក្រសួងនឹងមានវិធានការដាក់វិន័យរដ្ឋបាលចំពោះសាមីខ្លួននោះ ។ វិន័យរដ្ឋបាលនោះមានជាអាទិ៍ ការព្យួរការងាររយៈពេល ៣ខែ ឬ រហូតដល់ការបណ្តេញចេញពី ក្របខ័ណ្ឌមន្ត្រីរាជការ ។

**ប្រការ ៥ :** នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មត្រូវរៀបចំ :

- កន្លែងសមរម្យមួយនៅជាន់ក្រោមនៃអាគារលេខ ១៦១ ផ្លូវលេខ ១១៨ ( អាគារនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ) ដើម្បីទទួលភ្ញៀវ ទទួលពាក្យសុំ និង ប្រគល់ពាក្យសុំ ឬចម្លើយ អោយភ្ញៀវវិញ ។ កន្លែងនោះមិនត្រូវមានអ្វីបិទបាំងឡើយ ។
- រៀបចំជាស្រេចនូវរូបមន្ត ឯកសារ បង្កាន់ដៃ ដែលមានចែងក្នុងប្រការ២ ខាងលើ ។

- ណែនាំមន្ត្រីគ្រប់ជាន់ថ្នាក់ក្នុងនាយកដ្ឋាន អោយផ្តល់មតិលើសំណុំរឿងនានាក្នុងកាលកំណត់មួយជាក់លាក់ ហើយធ្វើយ៉ាងណាអោយសំណុំឯកសារនោះបានឆ្លងគ្រប់លំដាប់ថ្នាក់ក្នុងនាយកដ្ឋានក្នុងរង្វង់ ៤ ម៉ោង ។

**ប្រការ ៦ :** អគ្គនាយកដ្ឋានបច្ចេកទេសមានភារកិច្ចពិនិត្យសំណុំរឿង និងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួងក្នុងរង្វង់លើសពី ២ម៉ោង បន្ទាប់ពីទទួលសំណុំរឿង ។

**ប្រការ ៧ :** អនុរដ្ឋលេខាធិការទទួលបន្ទុកការងារ **GSP/MFN** ត្រូវពិនិត្យសំណុំរឿងនិងធ្វើការសំរេចវិជ្ជមាន ឬអវិជ្ជមាន ក្នុងរង្វង់ពេល ៤ ម៉ោងក្រោយពីការទទួលសំណុំរឿង ។

**ប្រការ ៨ :** ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវបំពេញការងារចោះលេខសម្ងាត់ បោះត្រា និងចុះលេខក្នុងរង្វង់មិនលើសពី ១ម៉ោងក្រោយពីទទួលសំណុំរឿងនីមួយៗ ។

**ប្រការ ៩ :** អគ្គាធិការដ្ឋានចាត់តាំងមន្ត្រីអធិការកិច្ចពីររូប ដើម្បីស្រាវជ្រាវរយៈពេលដែលសំណុំរឿងឆ្លងកាត់តំណាក់កាលនីមួយៗ ហើយរាយការណ៍ជូនរដ្ឋមន្ត្រី អំពីមន្ត្រីដែលពិនិត្យសំណុំរឿងលើសកាលកំណត់ដើម្បីមានវិធានការអប់រំ ព្រមាន ឬ ដាក់វិន័យ ។

**ប្រការ ១០ :** ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុកការងារ **GSP/MFN** ឯកឧត្តមអគ្គនាយកបច្ចេកទេស លោកនាយកខុទ្ទកាល័យរដ្ឋមន្ត្រី លោកប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម លោកស្រីប្រធាននាយកដ្ឋានរដ្ឋបាល ត្រូវទទួលខុសត្រូវអនុវត្តប្រកាសនេះអោយបានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ១១ :** ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ នេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ហត្ថលេខា និងត្រា
ចម ប្រសិទ្ធ

★★★

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

### ប្រកាសលេខ ១៧៨ ឧក.ប្រក

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេច នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ១២៥៦/៩៨ គ.វ.ក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៥១៦ ពអ.ស ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់សាលាក្រុងភ្នំពេញស្តីពីការអនុញ្ញាតអោយសាងសង់អាគារកាត់ដេរ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ញូ អូរៀន ( ខេមបូឌា ) ហ្គារម៉ែន ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៩

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន ញូ អូរៀន ( ខេមបូឌា ) ហ្គារម៉ែន (NEW ORIENT (CAMBODIA) GARMENT Co, LTD ) តំណាងដោយលោក GUO YA HONG សញ្ជាតិ ចិន អាយុ ៣៩ ឆ្នាំ អាស័យដ្ឋាន ១៥៥៨ PIONEER STREET BREA, CA 9281 USA កាន់លិខិតឆ្លងដែនលេខ ១៥៥៦២១១៨១ ចុះថ្ងៃទី១១-១២-១៩៩៧ បង្កើត “រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ” ដែលមានឈ្មោះថា “ រោងចក្រកាត់ដេរ ញូរៀន (ខេមបូឌា) ហ្គារម៉ែន “ មានទីតាំងនៅអាគារ C1 នៃប្លង់សាងសង់លេខ ៧៥ សជ/៩៨ ចុះថ្ងៃទី២៦-៣-១៩៩៨ ស្ថិតនៅតាមបណ្តោយផ្លូវពីស្ពានីយវិទ្យុស្ទឹងមានជ័យ ទៅពោធិ៍ចៅ ភូមិត្រពាំងថ្លឹង សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៣ :** ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលអំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ។

**ប្រការ ៤ :** រោងចក្រនេះត្រូវបានអនុញ្ញាតអោយ “ កាត់ ដេរ សំលៀកបំពាក់ ” ទៅតាមគំរូដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៥ :** រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្មពី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៦ :** ក្រុមហ៊ុនត្រូវលើកបង្ហាញ “ ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ ៧ :** ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៨ :** ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន ញូ រៀន ( ខេមបូឌា ) ហ្គារម៉ែន ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការៈ ៩ : ប្រកាសនេះមានអានុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

ស៊ុយ សែម

★★★

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## ប្រកាសលេខ ២០៤ ឧក.ប្រក
## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេច នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ២៤៧៥/៩៨ គ.វ.ក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញកិច្ចសន្យា ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៩៧ រវាងក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រុមហ៊ុន ខូវជីលី
- បានឃើញលិខិតលេខ ១១១ សហវ.ទរ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ខេមបូឌា ដូនណីនីញ៉ូង លីមីធីត ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ១៩៩៩

### សំរេច

ប្រការៈ ១ : អនុញ្ញាតអោយក្រុមហ៊ុន ខេមបូឌា ដូនណីនីញ៉ូង លីមីធីត ( CAMBODIA DONEUNION LIMITED. ) តំណាងដោយលោក WANG YI SHENG សញ្ជាតិ ចិន អាយុ ៣៩ ឆ្នាំ អាស័យដ្ឋាន N⁰ 18, Lane 3st Fong Tiangzi Goung Zhin , CHINA កាន់លិខិតឆ្លងដែនលេខ P 141777402 ចុះថ្ងៃទី០៣-៥-១៩៩៥ បង្កើត "រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ" ដែលមានឈ្មោះថា " រោងចក្រកាត់ដេរ ខេមបូឌា ដូនណីនីញ៉ូង ទី២ " មានទីតាំងស្ថិតនៅអតីត រោងចក្រវេចខ្ចប់ស្ទឹងមានជ័យ ផ្លូវសម្តេចមុនីរ៉េត សង្កាត់ ស្ទឹងមានជ័យ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និង ស៊េរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាព ផលិតផលហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូន ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ "កាត់ -ដេរ ចាក់ សំលៀកបំពាក់" ទៅតាមគំរូដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្មពី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន ខេមបូឌា ដូនណេនីញ៉ូង លីមីធីត ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអានុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

ស៊ុយ សែម

***

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## ប្រកាសលេខ ២២៩ ឧក.ប្រក

***

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេច នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ២៥០៧/៩៨ គ.វ.ក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញលិខិតលេខ ៩៦៨ ឧត.ស ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់សាលាក្រុងភ្នំពេញ ស្តីពីការអនុញ្ញាតអោយបើកទីតាំងរោងចក្រកាត់ដេរ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ទ្រីនុងហ្គាល កូម៉ារ៉ា ហ្គាមិន អ៊ិនដឹស្រ្ទី ខូ ..,លីមីតធីត ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ១៩៩៩

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ទ្រីនុងហ្គាល កូម៉ារ៉ា ហ្គាមិន អ៊ិនដឹស្រ្ទី ខូ ...លីមីតធីត ( TRINUNGGAL KOMARA GARMENT INDUSTRY Co, LTD.) តំណាងដោយលោក KARDI KOH សញ្ជាតិ សិង្ហបុរី អាយុ ៤៨ ឆ្នាំ អាស័យដ្ឋាន 59, Mulberry Ave, SINGAPORE 348401 កាន់លិខិតឆ្លងដែនលេខ S 2574862 Z ចុះថ្ងៃទី៣១-១០-១៩៩៥ បង្កើត “រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ” ដែលមានឈ្មោះថា “ រោងចក្រកាត់ដេរ ទ្រីនុងហ្គាល កូម៉ារ៉ា ហ្គាមិន អ៊ិនដឹស្រ្ទី ខូ ..,លីមីតធីត “មានទីតាំងស្ថិតនៅ អតីតមូលដ្ឋានឃ្លាំង ការិយាល័យទី៤ នៃអគ្គសេនាធិការដ្ឋាន ភូមិទឹកថ្លា សង្កាត់ ទឹកថ្លា ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និង ចំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាព ផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូន ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ “កាត់ - ដេរ សំលៀកបំពាក់” ទៅតាមគំរូដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្មពី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ “ ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន

ទ្រីនុងប្រុកាល កូម៉ូរ៉ា ព្រោមិន ម៉ិនជីស្រ្តី ខូ ...លីមីតធីត ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗ ខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអានុភាព អតិរេក ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

ស៊ុយ សែម

★★★

## ៣-នីស្តីការរដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៩

### ប្រកាសលេខ ១២៨ អយក.ប្រក

### ស្តីពីការបើក វិទ្យាល័យ ហ៊ុន សែន "ក្រគរ" ស្ថិតនៅក្នុង ឃុំ ក្បាលត្រាច ស្រុក ក្រគរ ខេត្ត ពោធិ៍សាត់

***

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៩២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជនកីឡា
- បានឃើញសេចក្តីណែនាំលេខ ៦៦ អ.ចអម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១ កំរិត២
- យោងលិខិតលេខ ១១២០/១២ អយក.ពស ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៨ របស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តពោធិ៍សាត់
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកវិទ្យាល័យដែលមានឈ្មោះថា : វិទ្យាល័យ ហ៊ុន សែន " ក្រគរ " គាប់ពីឆ្នាំសិក្សា ១៩៩៨-៩៩ តទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣ :** នាយក - នាយករងវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សា ចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាន នាយកដ្ឋាន ហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្តពោធិសាត់ និងនាយកវិទ្យាល័យសាមីមាន ភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ហត្ថលេខា និងត្រា

តុល ឡោះ

***

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

## ប្រកាសលេខ ១២៩ អយក.ប្រក

### ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យ ដើមឫស ទៅជាអនុវិទ្យាល័យ ហ៊ុន សែន " ដើមឫស " ស្ថិតនៅក្នុង ឃុំ ដើមឫស ស្រុក កណ្តាលស្ទឹង ខេត្ត កណ្តាល

***

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ

- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជនកីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទអ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៣ ស្តីពីការបើកសាលាមធ្យមសិក្សាកម្រិត១ កម្រិត២
- យោងលិខិតស្នើសុំ របស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យ ដើមឫស ស្រុក កណ្តាលស្ទឹង ខេត្ត កណ្តាល ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដោយមានការឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្តាល និងអភិបាលខេត្ត កណ្តាល
- តាមសេចក្តីយល់ព្រមរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សំរេច

**ប្រការ ១ :** អនុញ្ញាតអោយប្តូរឈ្មោះ អនុវិទ្យាល័យ ដើមឫស ទៅជាអនុវិទ្យាល័យ ហ៊ុន សែន " ដើមឫស " ចាប់ពីឆ្នាំ សិក្សា ១៩៩៨-៩៩ តទៅ ។

**ប្រការ ២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សា ចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងប្រធាន នាយកដ្ឋាន ហិរញ្ញវត្ថុ នៃក្រសួង អប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកណ្តាល និងនាយកអនុវិទ្យាល័យ សាមីមាន ភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ហត្ថលេខា និងត្រា

តូល ឡោះ

***

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩

## ប្រកាសលេខ ១៣៥ អយក.ប្រក

## ស្តីពីការបើក សាលាបឋមសិក្សា " ហ៊ុន សែន អញ្ចាញ "

***

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកប/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក សៀមរាប ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៨ ដែលមានចំណារឯកភាពរបស់ អភិបាលខេត្តសៀមរាប លេខ ១២៥៩ ខសរ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៩៨
- តាមសេចក្តីឯកភាព របស់នាយកដ្ឋានបឋមសិក្សា និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** បើកសាលាបឋមសិក្សា " ហ៊ុន សែន អញ្ចាញ " ជាសាលាបឋមសិក្សាពេញលក្ខណៈ ដែលមានទីតាំងស្ថិតនៅ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប ចាប់ពីឆ្នាំសិក្សា ១៩៩៨-៩៩ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា " ហ៊ុន សែន អញ្ចាញ " ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយករដ្ឋបាល ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកសៀមរាប នាយកសាលាបឋមសិក្សា "ហ៊ុន សែន អញ្ចាញ " មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ឹម សិទ្ធី

★★★

## ៤-នីតិការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩

**ប្រកាសលេខ ០៥២ បន.ប្រក**
**ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នាយកដ្ឋានគ្រប់គ្រងលេកអាកាសវិទ្យុទូរគមនាគមន៍ និង អាជ្ញាប័ណ្ណ**

***

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/ ០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើត ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញការចាំបាច់ ក្នុងការរៀបចំនាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុទូរគមនាគមន៍ និង អាជ្ញាប័ណ្ណ

## សំរេច

**ប្រការ ១ :** នាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុទូរគមនាគមន៍ និង អាជ្ញាប័ណ្ណ ជាអង្គភាពចំណុះក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

**ប្រការ ២ :** នាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុទូរគមនាគមន៍ និង អាជ្ញាប័ណ្ណ មានភារកិច្ចដូចតទៅ :

- រៀបចំតម្លើងស្តង់ដាវិទ្យុទូរគមនាគមន៍
- តាក់តែងឯកសារគំរូសំរាប់ផ្តល់ការយល់ព្រមដល់ការប្រើប្រាស់ស្តង់ដា
- តាក់តែងការអនុវត្តពត៌មានវិទ្យា
- សំរបសំរួលក្នុងការប្រើប្រាស់រយៈពេលវែងស្បិចរលកវិទ្យុ និងក្នុងការបញ្ចូលស្បិចរលកវិទ្យុក្នុងទំនាក់ទំនងអន្តរជាតិ
- ត្រួតពិនិត្យ និងតាមដានការប្រើប្រាស់រលកវិទ្យុ
- បែងចែកអាជ្ញាប័ណ្ណជូនបណ្តាការីដែលស្នើសុំ
- ដោះស្រាយវិវាទ និងវិបត្តិដែលមានជាមួយបណ្តាការី
- ផ្តល់ការយល់ព្រមលើបរិក្ខាររបស់បណ្តាការីដែលត្រូវតភ្ជាប់ទៅនឹងបណ្តាញទូរស័ព្ទ

**ប្រការ ៣ :** នាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុទូរគមនាគមន៍ និង អាជ្ញាប័ណ្ណ មានប្រធាននាយកដ្ឋានម្នាក់ និងអនុប្រធាននាយកដ្ឋានម្នាក់ ឬច្រើននាក់ជាជំនួយការ ។

**ប្រការ ៤ :** ប្រធាននាយកដ្ឋានត្រូវទទួលបន្ទុកលើការងារដែលមានចែងក្នុងប្រការ២ខាងលើ ។

**ប្រការ ៥ :** ប្រធាននាយកដ្ឋានមានភារកិច្ចដូចតទៅ :

- ដឹកនាំ ណែនាំ បង្ហាត់និងពន្យល់មន្ត្រីក្រោមឱវាទឲ្យចេះបំពេញការងាររបស់ខ្លួន ។
- ត្រិះរិះរកមធ្យោបាយ និង របៀបធ្វើការដែលផ្តល់ផលខ្ពស់បំផុតសម្រាប់នាយកដ្ឋាន ។
- ពិគ្រោះ និង ផ្តល់យោបល់ជូនអនុរដ្ឋលេខាធិការទទួលបន្ទុកនាយកដ្ឋាននូវកិច្ចការទាំងឡាយណាដែលថ្មី មុននឹងអនុវត្ត ។

- ធ្វើរបាយការណ៍ អំពីសកម្មភាពដែលនាយកដ្ឋានធ្វើបាន ជូនទៅអនុរដ្ឋលេខាធិការ ដើម្បីជ្រាបជាព័ត៌មាន និងសំរាប់ការប្រើប្រាស់របស់ក្រសួង ។
- ធ្វើកិច្ចការដទៃទៀតដែលក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ប្រគល់អោយ ។

ប្រការ ៦ ៖ ការិយាល័យនិងផ្នែករដ្ឋបាលដែលស្ថិតនៅក្នុងនាយកដ្ឋាននេះ ៖

១- ការិយាល័យគ្រប់គ្រងប្រេកង់ជាតិ ( National Frequency Management Office)

ការិយាល័យនេះមានភារកិច្ច ៖

- ធ្វើការសិក្សានិងចាត់ចែងវិសាលគមន៍ (Spectrum) សំរាប់ការប្រើប្រាស់ប្រេកង់ដោយពលរបើមូលដ្ឋាននៃឯកសាររបស់អង្គការអាយធីយូ ( ITU ) ជាគោល ។
- ស្វែងរកដំណោះស្រាយល្អ ក្នុងការបែងចែកវិសាលគមន៍ (Spectrum) ជូនក្រសួងនិងអង្គភាពនានាដែលពាក់ព័ន្ធ ។
- ធ្វើទំនាក់ទំនងជាមួយបណ្តាប្រទេសជិតខាង សំរាប់ Frequency Co-ordination ។
- បំពេញឯកសារចាំបាច់រួចផ្ញើជូនទៅអង្គការ ITU និងទទួលខុសត្រូវចំពោះមុខលើការប្រើប្រាស់វិសាលគមន៍ (Spectrum) ជូនអង្គការនេះក្នុងនាមព្រះរាជាណាចក្រកម្ពុជា។

២-ការិយាល័យអាជ្ញាប័ណ្ណប្រេកង់ ( Licensing Frequency Office )

ការិយាល័យនេះមានភារកិច្ច ៖

- ពិនិត្យបែបទស័ព្ទវិទ្យុនិងទីតាំងស្ថានីយ៍មុនពេលផ្តល់អាជ្ញាប័ណ្ណ ។
- ចេញអាជ្ញាប័ណ្ណសំរាប់ការផ្តល់ប្រេកង់ជូន អតិថិជនលើការប្រើប្រាស់បរិក្ខាវិទ្យុទូរគមនាគមន៍ ។
- ចេញអាជ្ញាប័ណ្ណសំរាប់ការផ្តល់ ច្បាប់បង្កើតភ្នាក់ងារនាំចូលបរិធានវិទ្យុទូរគមនាគមន៍និងច្បាប់ទទួលស្គាល់បរិធានវិទ្យុទូរគមនាគមន៍ ( Type Approval ) ។
- ធ្វើបទដ្ឋាននិងច្បាប់បំពីការណែនាំផ្សេងៗ សំរាប់រក្សាប្រសិទ្ធភាពអាជ្ញាប័ណ្ណ ។
- គូរគ្រប់បណ្តាញ Micro-wave នៅលើផែនទី ។

៣-ការិយាល័យត្រួតពិនិត្យប្រេកង់ ( Monitoring Frequency Office )

ការិយាល័យនេះមានភារកិច្ច ៖

- ធ្វើការវាស់ស្ទង់ជាប្រចាំ ដើម្បីធានានិងការពារការឆ្លងរំខានក្នុងការប្រើប្រាស់ប្រេកង់ ។
- ចុះធ្វើការត្រួតពិនិត្យ និងស្រាវជ្រាវ ដោយមានសហប្រតិបត្តិការពីភ្នាក់ងារមានសមត្ថកិច្ច ( បើចាំបាច់ ) ដើម្បីបង្ក្រាបនិងបំបាត់ស្ថានីយ៍ខុសច្បាប់ ។
- បញ្ចូលទិន្នន័យ Database សំរាប់ការគ្រប់គ្រងក្នុងប្រព័ន្ធកុំព្យូទ័រ ។
- ផ្តល់ទិន្នន័យប្លែកៗ ទៅការិយាល័យនានាដែលពាក់ព័ន្ធ សំរាប់ជាពត៌មានគ្រប់គ្រង ។

៤-ផ្នែករដ្ឋបាល

ផ្នែកនេះមានភារកិច្ច ៖

- គ្រប់គ្រងឯកសារ លិខិតស្នាមគ្រប់ប្រភេទ ( លិខិតចេញ- ចូល បញ្ជូនលិខិត ) ។
- គ្រប់គ្រងបែងចែកសម្ភារៈការិយាល័យ ។
- ធ្វើបញ្ជីបើកប្រាក់បៀវត្សសំរាប់មន្ត្រីរាជការក្នុងនាយកដ្ឋាន ។
- ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ ខែត្រីមាស ឆមាសប្រចាំឆ្នាំ ។

**ប្រការ ៧ :** ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុទូរគមនាគមន៍ និងអាជ្ញាប័ណ្ណត្រូវអនុវត្តន៍តាមខ្លឹមសារនៃប្រកាសនេះ ។

**ប្រការ ៨ :** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

សូ យុន

★★★